# បូជនីយដ្ឋាននៅប្រទេសឥណ្ឌា
# និងនេប៉ាល់

៖៖៖៖៖៖៖៖៖៖

*ការពន្យល់តាមផែនទីព្រះពុទ្ធយាងប្រោសសត្វ*

Where the Buddha walked

( *សូមមើលផែនទី* )

*សូមពុទ្ធបរិស័ទដែលបានអញ្ជើញទៅប្រទេសឥណ្ឌានិងនេប៉ាល់ដើម្បីទស្សនា និងថ្វាយបង្គំព្រះពុទ្ធស្ថាននានាមេត្តាពិនិត្យកន្លែងនិមួយៗនិងអានការពន្យល់ដោយសង្ខេបតាមពុទ្ធស្ថានមើលផ្ទាំងផែនទីនេះ ។*

**សង្កស្ស** Sankasya *ជាកន្លែងព្រះពុទ្ធយាងចុះពីឋានតាវតឹង្សក្រោយពីបានសំដែងព្រះអភិធម្ម៧គម្ពីរប្រោសព្រះមាតារួច ។ កន្លែងនោះមានចម្ងាយ៣១៥គ.មពីទីក្រុងនូវដែល្ហី ។ សសរស្តម្ភ១ដើម*(AshokaPillar) *ដាំនៅសំគាល់ថាព្រះពុទ្ធស្ថាន ។*

*កាលពីឆ្នាំ ២០០៣ ក្រុមយើងខ្ញុំបានចេញដំណើរពីរដ្ឋកាលីហ្វ័រនីញ៉ា ស.រ.អ. ទៅដល់ទីនោះ យើងខ្ញុំបានឃើញសសរស្តម្ភសល់មួយកំណាត់កំពស់ប្រហែល៤ម៉ែត្រៗ ដល់ចុងឆ្នាំ ២០០៥ យើងខ្ញុំបានទៅម្តងទៀតស្រាប់តែបាត់អស់តែម្តង ។ គួរឲ្យសង្វេគណាស់ ! ក៏ប៉ុន្តែក្នុងចិត្តនៃពួកយើងនៅតែចាំថាទីនោះជាព្រះពុទ្ធឋានមានសសរស្តម្ភសំគាល់នៅ ។*

**សាវត្ថី** Savatthi ( *បាលី* Pali ) – **ស្រាវស្ដី** Sravasti ( *សំស្ក្រឹត* Sanskrit )

*សម័យនេះហៅ* Saheth Maheth

សាវត្ថីជាទីតាំងនៅនៃវត្តជេតពន ក្នុងសម័យពុទ្ធកាលនិងក្នុងរជ្ជកាលព្រះបាទបសេនទិកោសល ។

ក្រោយពីយាងទៅគង់នៅក្រុងនេះ ដោយសុំយាងពីលោកសេដ្ឋី **អនាថបិណ្ឌិក** ។ លោកសេដ្ឋីកសាង**វត្តជេតពន** ថ្វាយព្រះសម្មាសម្ពុទ្ធ ។ នាង វិសាខា កសាងវត្ត **បុព្វារាម** ។ វត្តទាំង២ឧទ្ទិសចំពោះព្រះពុទ្ធសាសនា ។ ដោយសារការសំដែង **យមកប្បាដិហារ្យ** ដើម្បីផ្ចាញ់ពួកនិគ្រណ្ឋអន្ទិរថីមុនព្រះអង្គយាងទៅប្រោសព្រះមាតានៅស្ថានតាវតឹង្សក្នុងវស្សាទី៧ ក្រុងសាវត្ថីមានឈ្មោះល្បីខាងផ្នែកព្រះពុទ្ធសាសនាជាខ្លាំង ។

**វត្តជេតពន** Chettavanaram

ព្រះពុទ្ធបានគង់នៅក្នុងវត្តនេះចំនួន១៩វស្សារ ។ គេឃើញកន្លែងសំខាន់ៗជាច្រើនដូចជា :

- ដើមពោធិអានន្ទមានអាយុជាង២០០០ គឺតាំងតែព្រះពុទ្ធគង់នៅ ។ កាលណោះព្រះអានន្ទបានប្រើព្រះ **មោគ្គលាន** ឲ្យនិមន្តទៅយកផ្លែពោធិដោយឫទ្ធិពីដើមពោធិទី១នៅ**ពុទ្ធគយា** កន្លែងព្រះពុទ្ធត្រាស់ដឹងមកដាំតែមួយភ្លែតពោធិនោះក៏ធំភ្លាមរួចបែកមែកជា ៥ ។ ព្រះពុទ្ធបានគង់ចូលនិរោធសមាបត្តិ(ឈាន)ក្រោមដើមពោធិនោះ មួយយប់ ។ ហេតុដូច្នេះ យើងគួរទមស្សការហើយដើរព័ទ្ធដើមពោធិ ៣ ជុំផងដែរ ។ វត្តជេតពនជាទឹកដីព្រះអរហន្តនិមន្តដើរជាន់រាល់ថ្ងៃពីសម័យព្រះពុទ្ធគង់នៅ ។
- ឃើញកុដិព្រះអរហន្តជាច្រើន ។ - សាលាកាត់ក្តីកិក្ខុនីមានផ្ទៃពោះ ។ ព្រះពុទ្ធគង់ចាំព្រះវស្សានៅវត្តជេតពននេះចំនួន ៣ លើក គឺ :

លើកទី ១ វស្សាទី ១៤

លើកទី ២ វស្សាទី ២០ ដល់ ២៩

លើកទី ៣ វស្សាទី ៣៦ ដល់ ៤៤

- គេឃើញធម្មសភាសាលាជាកន្លែងប្រោសនាងបដាចារនិងផ្កាញ៉ាន់នាងចិញ្ចា ។

សូមជ្រាបថា អនាថបិណ្ឌិកសេដ្ឋីបានចំណាយប្រាក់ច្រើនកោដិទិញដី ។ ព្រះអង្គម្ចាស់ជេត ( ម្ចាស់ដី ) បញ្ជាឲ្យយកប្រាក់ក្រាលពេញដីទើបលក់ ។ លុះក្រាលមិនពេញ ទើបព្រះអង្គចូលដីខ្វះតែសុំដាក់ឈ្មោះព្រះអង្គ វត្តនេះក៏មានឈ្មោះ **វត្តជេតពន** ឡើង ។

ក្រុងសាវត្ថីនៅតាមដងស្ទឹង **អចិរវតី** បច្ចុប្បន្នហៅស្ទឹង **រប្តិនទី** ។ ស្ទឹងមិនឆ្ងាយប៉ុន្មានពីរបងក្រុងសាវត្ថីទេ។ ដោយសារឆ្លងកាត់ស្ទឹងនេះ កូនរបស់ **នាងបដាចារ** ទាំងពីរបានត្រូវស្លាប់ - ១ ដោយលង់ទឹក ១ ទៀតដោយខ្លែង ឆាប ។ ក្រោយមកទៀតនាងបួសស្តាប់ធម៌នៅវត្តជេតពនបានសម្រេចជាព្រះអរហន្តីមានងារថា **បដាចារថេរី** ។

នៅជិតវត្តនោះ គេឃើញព្រះរាជវាំងព្រះបាទបសេនទិកោសល- ឃ្លាំងមាសប្រាក់របស់អនាថបិណ្ឌិកសេដ្ឋី -ឃ្លាំងរបស់ឪពុកអង្គុលីមា- កន្លែងផែនដីស្រូបទេវទត្ត - កន្លែងផែនដីស្រូបនាងបញ្ចា - កូនភ្នំព្រះសម្តែង **យមកប្បាដិហារ្យ** ផ្ចាញ់ពួកនិគ្រណ្ឋអន្ទិរថីដែលប្រឆាំងនឹងព្រះអង្គពីរឿងលាភសក្ការៈនិងការចង់បំផ្លាញវត្តជេតពន ។ ក្រោយពីការសម្តែង ព្រះអង្គយាងទៅកាន់ព្រះវស្សាឯស្ថានតាវតឹង្សចំនួន៣ខែដើម្បីប្រោសព្រះមាតា ។ ព្រះអង្គយាងចុះមកវិញនៅឯ **សង្កស្សៈ** ដូចបានពណ៌នារួចមកហើយ ។

## វត្តបុព្វារាម

មហាឧបាសិកា **វិសាខា** ជាសោតាបន្នបុគ្គលតាំពីអាយុ៧ឆ្នាំបានសាងវត្ត **បុព្វារាម** អស់ប្រាក់ ២៧ កោដិ គឺទិញដី ៩ កោដិ - សាងសង់អស់ ៩ កោដិ - ធ្វើបុណ្យ៤ខែអស់៩កោដិ ។

ក្រុមបុរាណវត្ថុប្រទេសឥណ្ឌាមិនទាន់រកឃើញទីតាំងវត្ត **បុព្វារាម** នៅឡើយទេ ។

កាលបើបានមើលវត្តជេតពនរួចហើយ ពុទ្ធបរិស័ទតេងតែសួររក" ឯណាទៅវត្ត **បុព្វារាម** របស់ឧបាសិកា **វិសាខា** ?"

## **កបិលព័ស្តុ** Kapilavastu

ជាព្រះរាជវាំងព្រះពុទ្ធយាងចុះចាប់បដិសន្ធិនៅថ្ងៃព្រហស្បតិពេញបូរមី១៥កើត ខែ អាសាឍ ឆ្នាំ រកា ។ ក្នុងវ័យកុមារភាពព្រះអង្គក៏គង់នៅក្នុងវាំងនេះ ។ ព្រះពុទ្ធយាងចេញទៅសាងព្រះផ្នួសពីព្រះរាជវាំងនេះដែរ ។សព្វថ្ងៃនៅក្នុងប្រទេសនេប៉ាល់ ។ ឯកបិលព័ស្តុនៅក្នុងប្រទេសឥណ្ឌាគ្រាន់តែជាកន្លែងពួកក្សត្រតម់មកនៅក្រោយពេលដែលគេសម្លាប់ច្រើនណ្ណោះ ។ ព្រះពុទ្ធមិនបានគង់នៅទីនោះទេ ។

## **លុម្ពិនី** Lumbini

ជាពុទ្ធសំវេជ្ជនិយដ្ឋានទី ១ ។ កន្លែងព្រះប្រសូត្រ ។ ព្រះប្រសូត្រនៅថ្ងៃសុក្រពេញបូរមី ១៥ កើតខែវិសាខឆ្នាំច ។

លុម្ពិនីជាឈ្មោះនៃឧទ្យានសាលព្រឹករបស់ស្តេចសក្យៈវង្ស នៅចន្លោះក្រុងកបិលព័ស្តុនិងក្រុងទេវទហៈ ។ កបិលព័ស្តុជារាជធានីនៃដែនសក្កៈ សោយរាជ្យដោយព្រះបាទសុទ្ធោទនៈជាពុទ្ធបិតា ។ ទេវទហៈជារាជធានីនៃដែនកោលិយៈ សោយរាជ្យដោយព្រះបាទអញ្ជនៈជាបិតារបស់ពុទ្ធមាតាគឺព្រះនាងសិរិមហាមាយាទេវី ។ សព្វថ្ងៃលុម្ពិនីឋិតនៅក្នុងប្រទេសនេប៉ាល់ ។

ដោយគោរពតាមប្រពៃណីក្នុងសម័យនោះ ព្រះនាងសិរិមហាមាយាទេវីត្រូវតែទៅប្រសូត្រព្រះរាជបុត្រឯនគរព្រះមាតាបិតាឯក្រុងទេវទហៈ ។ ព្រះរាជដំណើរដល់លុម្ពិនីក៏ប្រសូត្រព្រះពោធិសត្វ ។ ព្រះអង្គប្រសូត្រចាកគភ៌ហាក់ដូចព្រះធម្មកថិកថិកចុះចាកធម្មាសនៈ ( គ្រែទេស ) យាង ៧ ជំហានទៅទិសខាងជើង រួចលើកព្រះហស្តស្តាំបន្លឺនូវឧទានវាចាថាៈ

- អាត្មាអញខ្ពង់ខ្ពស់បំផុតក្នុងលោក -

- អាត្មាអញប្រសើរបំផុតក្នុងលោក -

- អាត្មាអញចម្បងបំផុតក្នុងលោក -

- នេះជាជាតិទីបំផុតរបស់អាត្មាអញ -

- ភពថ្មីមិនមានដល់អាត្មាអញទៀតទេ -

ក្នុងពេលជាមួយគ្នានោះ សហជាតិវត្ថុ ៧ យ៉ាង គឺ ព្រះនាងយសោធរាពិម្ពា ឆន្នអាមាត្យ កាឡុទាយីមហាអាមាត្យ មហាពោធិព្រឹក្ស សេះកណ្ឋក ព្រះអានន្ទ និង កំណប់ទ្រព្យទាំង ៤ ក៏កើតមានប្រាកដឡើង ។

ដទៃពីនេះ ស្តេចក្នុងប្រទេសទាំង៤ គឺ ព្រះបាទពិម្ពិសារ ក្នុងដែនមគធៈ ព្រះបាទបសេនទិ ក្នុងដែនកោសល ស្តេចចណ្ឌប្បជ្ជោត ក្នុងទីក្រុងឧជ្ជេនីនិងព្រះបាទឧទេន ក្នុងទីក្រុងកោសម្ពី ក៏បានកើតក្នុងថ្ងៃនោះ ។

ព្រះបាទធម្មាសោកបានយាងទៅលុម្ពិនីក្នុងឆ្នាំ២៤៤មុនគ្រឹស្តសករាជហើយ បានសាង សសរស្តម ( Asoka pillar ) មួយដើមទុកនៅទីនោះ ។

## រាមគ្រាម Ramgram

មុនសម័យពុទ្ធកាល រាមគ្រាមជារដ្ឋធានីនៃដែនកោលិយៈមុនទីក្រុងទេវទហៈ ។ ក្រោយពីពេលបូជាព្រះសពរួច ទោណព្រាហ្មបានយកព្រះសារីរិកធាតុមួយចំណែកទៅដំកល់នៅទីនោះ ។ រាមគ្រាមនៅក្នុងប្រទេសនេប៉ាល់មានចម្ងាយ៦៥ គ.ម.ពីលុម្ពិនីតាមផ្លូវទៅ កាត្មាន់ឌូ khatmamdu ឆ្លងកាត់ស្ទឹងរោហិណី ។

## វេសាលី Vaishali

- ជាកន្លែងព្រះពុទ្ធដាក់ព្រះជន្មាយុសង្ខារ នៅថ្ងៃអាទិត្យពេញបូរមី១៥ កើតខែពិសាខឆ្នាំម្សាញ់ ។

- កន្លែងកំណើតព្រះភិក្ខុនី
- កន្លែងកំណើតរតនសូត្រ ( ធម៌សូត្ររម្ងាប់ជម្ងឺផ្សេងៗ ) ។
- កន្លែងស្វាថ្វាយទឹកឃ្មុំចំពោះព្រះពុទ្ធ
- កន្លែងធ្វើសង្គាយនាលើកទី ២ ។

សព្វថ្ងៃ *វេសាលី* នៅក្នុង*រដ្ឋប៊ីហា* Bihar ប្រទេសឥណ្ឌាមានចម្ងាយប្រមាណ ៥០គ.ម.ពីទីក្រុង**បត្នះ**បច្ចុប្បន្ន ។ **បាតលីបុត្រ**ឈ្មោះដើមក្នុងរាជ្យព្រះបាទធម្មាសោក។

ព្រះពុទ្ធទ្រង់យាងមកកាន់វស្សា ២ដងនៅវេសាលីនេះ គឺវស្សាទី៥និងវស្សាទី ៤៥ នៅវេឡុគ្រាម ( វេសាលី ) ។ កាលណោះព្រះពុទ្ធគង់នៅវត្ត វេឡុវ័ន វត្តព្រះពុទ្ធសាសនាទី១នៅក្រុងរាជគ្រិស្ត ។

គ្រាមួយនោះ ក្រុងវេសាលី នៃដែនវជ្ជីកើតមហន្តរាយ ៣ យ៉ាង គឺ ១អហិវាទរោគ ២.ទុរ្ភិក្ស ៣.បិសាចយាយីធាតៅសម្លាប់មនុស្ស ។ ស្តេចលិច្ឆវីនៃដែនវជ្ជីបានសុំយាងព្រះពុទ្ធមកជួយទើបបានស្ងប់ស្ងាត់ ។

នាង**អម្ពបាលី** ស្ត្រីសោភិនីប្រចាំក្រុងវេសាលី បានថ្វាយចំការស្វាយដល់ព្រះសម្មាសម្ពុទ្ធក៏នៅទីងក្រុងនេះ ។ ក្រោយមកបួសជាភិក្ខុនីបានសម្រេចជាព្រះអរហន្ត ។

## **កុសិនារា** Kushinagar

ព្រះពុទ្ធសំវេជ្ជនិយដ្ឋានទី ៤ ។ កន្លែងព្រះពុទ្ធបរិនិព្វានទៅថ្ងៃអង្គារពេញបូណ៌មី ១៥កើតខែពិសាខឆ្នាំម្សាញ់ ។ ក្រុងនេះមានចម្ងាយ១៨១ គ.ម.ពីលុម្ពិនី ។

**កុសិនារា**ធ្លាប់ជាក្រុងដ៏រុងរឿងមួយពីសម័យមុនពុទ្ធកាលឈ្មោះ**កុសាវតី**ក្នុងរឿងព្រះបាទកុសរាជ (សូមស្តាប់រឿងព្រះបាទកុសរាជនៅទំព័រ ប៊ុត សាវង្ស ) ។

មុនយាងមកបរិនិព្វានឯក្រុងកុសិនារា ព្រះពុទ្ធបានគង់ចាំវស្សានៅ *វេឡុគ្រាម* ជិតក្រុងវេសាលី ។ ក្រោយពីចាំព្រះវស្សាទី ៤៥ រួចហើយ ព្រះអង្គទ្រង់ត្រាស់ទៅ

កាន់ព្រះអនន្ទថា : ម្នាលអានន្ទ ! ឥឡូវនេះតថាគតចាស់ជរាណាស់ហើយ ជន្មាយុតថាគតគ្រប់គ្រាន់ហើយ ដំណើរប្រកាសផ្សាយធម៌វិន័យរបស់តថាគតក៏ឈ្មោះថាចប់ត្រឹមបុណ្ណេះ ។ ឥឡូវនេះតថាគតមានជន្មាយុគ្រប់៨០ឆ្នាំ ដូចជារទេះចាស់គ្រាំគ្រាដែលអាចលឿនទៅមុខបានដោយការជួយទុបទល់ដោយម៉ឺងម៉ាត់យ៉ាងណាមិញឯរាងកាយតថាគតដែលអាចប្រព្រឹត្តទៅបានដោយការអបស្ទបដូច្នោះដែរ ។

ផុតរដូវភ្លៀង ព្រះអង្គបានយាងចេញទៅកាន់ទ្វារក្រុង ទ្រង់ព្រះតម្រាស់លាក្រុងវេសាលីនៃមហាជនបទវជ្ជីថា : ឱវេសាលី នេះជាការឃើញចុងក្រោយបង្អស់នៃតថាគត...។ រួចហើយ ព្រះអង្គក៏បន្តដំណើរកាត់ភូមិតូចធំជាច្រើនសំដៅទៅក្រុងកុសិនារា ។ ប៉ុន្តែព្រះអង្គបានយាងទៅដល់ត្រឹមតែក្រុងបាវាត្រូវឈប់សំរាកមួយរាត្រី ។ នាយចុន្ទជាជាងដែកនៅទីនោះបានយាងព្រះអង្គឲ្យគង់ក្នុងព្រៃស្វាយរបស់ខ្លួនហើយទឹងថ្វាយចង្ហាន់នៅព្រឹកថ្ងៃស្អែក ។

គ្រាន់តែឆាន់រួចមិនយូរប៉ុន្មាន ព្រះអង្គមានអាពាធកាន់តែខ្លាំងឡើង ៗ ជាងមុន ។ លុះធ្វើអនុមោទនារួចហើយ ព្រះអង្គក៏បន្តដំណើរទៅទៀត ។ លុះទៅដល់ជិតក្រុង ព្រះអង្គប្រើឲ្យព្រះអានន្ទទៅសុំពួកស្តេចមល្លក្សត្រដើម្បីបរិនិព្វាន ។ ពួកមល្លក្សត្រថ្វាយឧទ្យានសាលព្រឹក្សឲ្យព្រះអង្គបរិនិព្វាន ។

ពេលទៀបបរិនិព្វាន ព្រះពុទ្ធអង្គបានផ្ទំសីហសេយ្យាលើគ្រែ បែរព្រះសិរទៅទិសខាងជើង បែរព្រះភក្រទៅទិសខាងលិច បានត្រាស់ហៅអានន្ទដែលកំពុងយំសោកឲ្យចូលមកជិត ហើយដាស់តឿនដោយព្រះវាចាយ៉ាងទន់ភ្លន់ថា :

- ម្នាលអានន្ទ ! ចូរអ្នកកុំយំសោក ចូលមកក្នុងទីជិតតថាគតនឹងប្រាប់អ្នកនូវពត៌មាន : បរិស័ទ៤ជំពូកគឺ ភិក្ខុ ភិក្ខុនី ឧបាសកនិងឧបាសិកា មិនចាំបាច់បូជាតថាគតដោយអមិសវត្ថុណាមួយទេ ការបូជាដោយសេចក្តីប្រតិបត្តិនូវធម៌វិន័យនោះ ទើបឈ្មោះថាការបូជាដ៏ប្រសើរលើសលប់ ! ម្នាលអានន្ទ ! អ្នកកុំស្មាយតថាគតធ្វើអ្វី ធម៌និងវិន័យដែលតថាគតបានសំដែងនិងបញ្ញត្តិហើយនោះជាគ្រូរបស់អ្នក ។

ម្នាលអានន្ទ ! ស្ថាន ៤ កន្លែងគឺ-ទី១ ស្ថានដែលតថាគតបានប្រសូត្រ -ទី២ ស្ថានដែលតថាគតបានត្រាស់ដឹងនូវសម្មាសម្ពោធិ - ទី៣ ស្ថានដែលតថាគតបានសំដែងបឋមទេសនា ( ធម្មចក្រ ) -ទី៤ ស្ថានដែលតថាគតបរិនិព្វាន ។ ទាំង៤នេះ ចាត់ជា**សំវេជនិយដ្ឋាន** ដែលពុទ្ធបរិស័ទទាំងឡាយ ឬអ្នកជឿក្នុងសាសនាទូទៅគួរទៅមើលឲ្យឃើញដោយការសំដែងនូវសេចក្តីគោរពនិងសេចក្តីសង្វេគ ។ ជនឯណាបានទៅគោរពទីទាំង៤នោះ ហើយមិនធ្វើ អនន្តរិយកម្ម៤ គឺមិនបានសម្លាប់មាតា១ មិនបានសម្លាប់បិតា១ មិនបានបំបែកសង្ឃ១ និងមិនបានធ្វើឲ្យឈាមព្រះពុទ្ធពុះពោរ ១ ក្រោយពីស្លាប់ទៅអ្នកនោះមិនទៅកាន់អបាយភូមិឡើយ ។

ពេលមុនបរិនិព្វាន ព្រះពុទ្ធអង្គបានទទួលការថ្វាយបង្គំពីពួកមល្លក្សត្រទាំងឡាយនិងពី**សុភទ្ទបរិពាជក** ដែលមានអាយុ: ១២០ឆ្នាំហើយនោះ មានសរីរញ័រទទ្រើកបានវែកពុទ្ធបរិស័ទចូលទៅគាល់ព្រះពុទ្ធអង្គដើម្បីជួបព្រះអង្គបំបាត់ការសង្ស័យរបស់ខ្លួន ។ លុះបានស្តាប់ព្រះពុទ្ធដិកាចប់ ក៏អស់ការសង្ស័យបានសម្រេច **អរហត្តផល** ក្រោយគេបង្អស់ទាន់ព្រះពុទ្ធនៅមានព្រះជនទៅឡើយ។

ពេលចុងក្រោយបំផុត ព្រះពុទ្ធមានដិកាថា: ម្នាលភិក្ខុទាំងឡាយ ! ឥឡូវនេះតថាគតនឹងប្រាប់អ្នករាល់គ្នាថា សង្ខារធម៌ទាំងឡាយមានកិរិយាសូន្យទៅជាធម្មតា ចូរអ្នកញ៉ាំងកុសលឲ្យប្រព្រឹត្តទៅដោយសេចក្តីមិនធ្វេសប្រហែសចុះ ។

គ្រាន់តែទ្រង់ត្រាស់នូវពុទ្ធភាសិតនេះហើយ ព្រះអង្គទ្រង់បិទព្រះនេត្រទាំងគូចូលកាន់ឈានហើយបរិនិព្វានក្នុងពេលជិតថ្ងៃរះនាថ្ងៃអង្គារពេញបូរមី១៥១កើតខែពិសាខឆ្នាំម្សាញ់បញ្ចស័ក ។

**បត្នះ** Patna

បត្នះជាកន្លែងធ្វើសង្គាយនាលើកទី៣ មានចម្ងាយ៩០ គ.ម.ពីនាលន្ទានិង១០២ គ.ម.ពីរាជគ្រិស្ត ។ សម័យព្រះបាទធម្មាសោក បត្នះ ឬ **បាតលីបុត្រ** ជារាជធានី ។

**នាលន្ទា** Nalanda

**ព្រះសារីបុត្ត** បានប្រសូត្រនិងបរិនិព្វាននៅកន្លែងនេះ ។ គេឃើញ **ស្តូប** និងសកលវិទ្យាល័យព្រះពុទ្ធសាសនានៅទីនេះមានចម្ងាយ១៣ គ.ម.ពី **រាជគ្រិស្ឋ** ៨០ គ.ម.ពី **ពុទ្ធគយា** ។

អ្នកប្រាជ្ញចិនឈ្មោះ ហ្វួន សាង បានទៅទស្សនាហើយសិក្សានៅសកលវិទ្យាល័យនេះចំនួន១៥ឆ្នាំកាលពីគ.ស.៦២៩ មានអក្សរចារិកតាំងនៅទីនោះ ។

នៅមានត.........................